# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសលើកទី៩ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១. ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២

**២. ទីកន្លែង៖**

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

៣.១ ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៣.២ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាយ(Zoom)ជានី ខេត្ត និងអង្គការពាក់ព័ន្ធដែលចូលរួមផ្ទាល់ចំនួន២៣រូប និងតាមប្រព័ន្ធអនឡាយចំនួន៤៤រូប សរុបចំនួន៦៧រូប។

**៤. របៀបវារៈ៖**

៤.១ មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២ បច្ចុប្បន្នភាពយុទ្ធវិធីជំរុញខ្លាំងក្លាការបង្ការ ថែទាំ និងព្យាបាលបន្ត ដល់ក្រុមប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ បង្ហាញដោយ **លោកវេជ្ជ. កាអឿន ចិត្រា** អនុប្រធានការិយាល័យបច្ចេកទេសនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។

៤.៣ មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. លទ្ធផល ៖**

ថ្ងៃសុក្រ ១៣រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៩ ឆ្នាំ២០២២ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តាមប្រព័ន្ធ ZOOM និងដោយផ្ទាល់នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ដោយមានការចូលរួមពីសមាជិក សមាជិកាមន្ត្រីបច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការដៃគូ។

ដំណើរការនៃកិច្ចប្រជុំមាន៖

៥.១ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អះអាងថា នៅឆ្នាំ២០២១នេះ កម្ពុជាសម្រេចបាន ៨៤ % នៃអ្នកផ្ទុកមេរោគអេដស៍ ទាំងអស់បានដឹងពីស្ថានភាពរបស់ខ្លួន ក្នុងចំណោមអ្នកដែលដឹងថាខ្លួនមានផ្ទុកមេរោគអេដស៍ ៩៩% បានធ្វើរោគវិនិច្ឆ័យ។ ឯកឧត្តមបណ្ឌិត បានលើកឡើងទៀតថា សម្រាប់អ្នកទទួលការព្យាបាល បាន៩៧% នៃអ្នកផ្ទុកមេរោគអេដស៍ ដែលបានទទួលការព្យាបាលមានអត្រាមេរោគតិចបំផុតមិនអាចជាការគម្រាមចំពោះសុខភាពរបស់អ្នកផ្ទុក។ ទន្ទឹមនឹងនោះក្រុមប្រឹក្សាបច្ចេកទេសមានតួនាទីជាសេនាធិការបច្ចេកទេស ជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការរៀបចំគោលនយោបាយជាតិប្រយុទ្ធនឹងជំងឺអេដស៍ រៀបចំយុទ្ធសាស្ត្រ សម្រាប់អនុវត្តគោលនយោបាយជាតិរៀបចំផែនការសកម្មភាព ជួយណែនាំការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ដើម្បីឆ្លើយតបដោយមានប្រសិទ្ធភាពទៅនឹងតម្រូវការនៃស្ថានភាពមេរោគអេដស៍។ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្ត ដើម្បីសម្រេចបាននូវគោលដៅ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥។

តាមលទ្ធផលស្រាវជ្រាវរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគបានបញ្ជាក់ថា៖

៥.២ ស្ថានភាពក្រុមប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ ទូទៅមានអត្រា0.6%(ក្នុងនោះមានស្ត្រីបម្រើសេវាកំសាន្តឯករាជ្យមាន ១១.៨%, ស្ត្រីបម្រើសេវាកំសាន្តនៅតាមហាង ខារ៉ាអូខេ ម៉ាស្សាមាន ៣.២%,បុរសស្រលាញ់បុរស ៤.0%, ស្ត្រីបំលែងភេទមាន៩.៦% ក្រុមដក់គ្រឿងញៀន៥.៧% និងក្រុមចាក់គ្រឿងញៀនមាន ១៥.២%)។ ប៉ុន្តែដោយឡែកក្រុមប្រើប្រាស់ថ្នាំញៀនគឺមានទិន្នន័យមិនបានពិតប្រាកដ ដោយសារពួកគាត់ពិបាកក្នុងការទំនាក់ទំនង។ ដំណែកឯស្ត្រីមួយចំនួនក៏មិនមកទទួលសេវាដែល នៅតែគិតពីការរើសអើង ។សម្រាប់អ្នកមកទទួលសេវាទៀងទាត់បានតែ៦0% ប៉ុណ្ណោះ។

៥.៣ វិធីសាស្ត្របង្ការការចម្លងមេរោគអេដស៍ មានតាមប្រព័ន្ធផ្សព្វផ្សាយដូចជា ឡានវ៉ែន ការពិនិត្យសុខភាពចុះអប់រំផ្ទាល់តាមបែបនិម្មិត តាមការស្វែងរកដៃគូ និងតាមរយៈប្រើថ្នាំ PrEP និង PEP ជាដើម ។

៥.៤ អត្រាផ្ទុកមេរោគអេដស៍ ចំពោះប្រជាជនប្រឈមមុខខ្ពស់នៅឆ្នាំ២០២១មាន៖

- ក្រុមស្ត្រីបម្រើសេវាកំសាន្តសប្បាយមាន: Q1=7.0%, Q2=0.4%,Q3=0.4%,Q4=0.6%
- ក្រុមបុរសស្រលាញ់បុរសមាន: Q1=2.4%, Q2=3.0%,Q3=1.9%,Q4=1.6%
- ក្រុមបំលែងភេទមាន: Q1=4.1%, Q2=8.5%,Q3=4.1%,Q4=3.1%

- ក្រុមប្រើប្រាស់គ្រឿងញៀន: Q1=0.0%, Q2=0.0%,Q3=0.7%,Q4=0.4%

៥.៥ ចំនួនអតិថិជនដែលប្រើប្រាស់សេវាបង្ការមុនប្រឈមចាប់ពីត្រីមាសទី៣ ឆ្នាំ២០១៩មកត្រឹមត្រីមាសទី២ឆ្នាំ២០២២មានៈ

- ក្រុមស្ត្រីបម្រើសេវាកំសាន្តសប្បាយមាន: 490, 13%
- ក្រុមបុរសស្រលាញ់បុរសមាន: 2639, 69%
- ក្រុមបំលែងភេទមាន: 624, 16%
- ក្រុមប្រជាជនទូទៅ: 91, 2%

## ៥.៦ បញ្ហាជួបប្រទះ

- ក្រុមគោលដៅ ដែលមានប្រតិកម្មអេដស៍មិនព្រមប្រាប់ពីដៃគូរបស់គាត់។
- ក្រុមគោលដៅខ្លះជាស្ត្រីឯករាជ្យ ស្ត្រីនៅ តាមខារ៉ាអូខេ បុរសស្រលាញ់បុរស ស្រីស្រស់ ពិបាកប្រមូលផ្តុំ អប់រំផ្តល់ប្រឹក្សាតេស្តឈាម។
- ពិបាកគ្រប់គ្រងក្រុមគោលដៅដែលធ្វើការចល័តពីហាងមួយទៅហាងមួយទៀតនៅក្នុងខេត្ត ក្រៅខេត្ត និងដូរលេខទូរស័ព្ទ។
- ក្នុងឆ្នាំ២០២១បញ្ហាកូវីដកំពុងតែរីករាយដាល ហាងជាច្រើនត្រូវបានបិទ ហើយអាជ្ញាធរ បានរឹតបន្តឹង និងហាមឃាត់មិនឱ្យក្រុមការងារចុះធ្វើការអប់រំផ្ទាល់។
- មានការឃាត់ខ្លួនស្ត្រីឯករាជ្យ ពីសមត្ថកិច្ចយកទៅធ្វើតេស្តពាក់ព័ន្ធគ្រឿងញៀន និងបានបញ្ជូនទៅមណ្ឌលកែប្រែឱកាសខ្ញុំ ចំពោះបុគ្គលដែលមានពាក់ព័ន្ធនឹងគ្រឿងញៀនត្រូវបញ្ជូនទៅមណ្ឌលកែប្រែព្រៃស្ព។
- ក្រុមគោលដៅមួយចំនួនលាក់អត្តសញ្ញាណ ដូរឈ្មោះ លាក់ ថ្ងៃ ខែ ឆ្នាំកំណើត ពិបាកក្នុងការបង្កើតU-UIC ។

## ៥.៧ ដំណោះស្រាយ

- ដកឃ្លាសិន និងព្យាយាមសើុបសួររកមិត្តភក្តិរបស់គាត់តាម Facebook ហើយស្វែងរកតាមមិត្ត ឬព្យាយាមសាកសួរ។
- កំណត់ទីតាំង ពេលវេលាណាត់ជួបស្ត្រីបម្រើសេវាកំសាន្តឯករាជ្យ បុរសស្រលាញ់បុរស ស្រីស្រស់ ទំនាក់ទំនងតាមលេខ ទូរស័ព្ទជួបម្នាក់ផ្តល់ប្រឹក្សាម្នាក់។
- ចុះស្រង់ឈ្មោះក្រុមគោលដៅរួចផ្ទៀងផ្ទាត់ឈ្មោះតាមហាង ទំនាក់ទំនងតាមមិត្តភក្តិ តាមមេកា និងតាមបណ្តាញសង្គម។
- OW ព្យាយាមអប់រំ តាមបណ្តាញសង្គម និងណាត់ជួបដើម្បីធ្វើតេស្ត ចែកស្រោម និងផ្ញើរកញ្ចប់តេស្តដើម្បីធ្វើតេស្តខ្លួនឯង។

- ក្រុមការងារកម្មវិធីស្មាតហ្គីលព្យាយាមតាមដាន និងទំនាក់ទំនងអាជ្ញាធរ ដើម្បីទទួលបានព័ត៌មាន និងសម្រួលឲ្យពួកគាត់ទទួលបាន សេវាព្យាបាលចំពោះអ្នកដែលមានផ្ទុកមេរោគអេដស៍។
- ព្យាយាមកសាងទំនុកចិត្ត រហូតទទួលបានព័ត៌មានពីក្រុមគោលដៅ

**មតិយោបល់**

- ស្នើសុំតេស្តរកមេរោគអេដស៍ដោយខ្លួនឯង ឱ្យបានច្រើនជាងនេះ
- OW នៅមានកម្រិត គួរពង្រឹង និងបណ្តុះបណ្តាលពួកគាត់
- ពុំមានស្រោមគ្រប់គ្រាន់តាមផែនការ សូមមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគជួយគាំទ្រ
- ចំពោះអង្គការគួរតែមានចុះអនុស្សរណៈសហប្រតិបត្តិការជាមួយមន្ទីរសុខាភិបាល ដើម្បីងាយស្រួលក្នុងការសម្របសម្រួលកិច្ចការផ្សេងៗ និងប្រសិនបើមានបញ្ហាអ្វីគួរតែរាយការណ៍មកមន្ទីរ
- ចំពោះបញ្ហាប្រឈមមិនគួរប្រើពាក្យមួយស្មោះនឹងមួយបានទេ បើដូចនេះពួកគាត់នឹងដាច់បាយ
- ជម្រុញការធ្វើតេស្តឈាម តាមរយៈការអប់រំបន្តរវាងដៃគូរបស់ពួកគាត់

នាឱកាសនោះ ឯកឧត្តម អគ្គលេខាធិការប្រធានអង្គប្រជុំបានបន្តថា ប្រទេសកម្ពុជាយើង នៅមានឧបសគ្គក្នុងការសម្រេចឱ្យបាននូវគោលដៅ៩៥. ទី១៖ ដែលនៅពេលនេះទើបទទួលបានត្រឹម ៨៤ភាគរយ ដែលនៅឆ្ងាយពីគោលដៅកំណត់ និងដែលទាមទារឱ្យយើងទាំងអស់គ្នាត្រូវបន្តរួមគ្នា រកវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាពផ្សេងៗទៀតដើម្បីសម្រេចគោលដៅនេះ។ កម្មវត្ថុនៃកិច្ចប្រជុំលើកទី៩នេះគឺធ្វើការពិនិត្យពិភាក្សាលើ "យុទ្ធវិធីជំរុញខ្លាំងក្លាការបង្ការ ថែទាំ និងព្យាបាលបន្តដល់ក្រុមប្រជាជនគន្លឹះ (Boosted Continuum of Prevention to Care and Treatment for Key Populations)"។ ក្រុមប្រជាជនគន្លឹះ ដែលជាក្រុមប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍រួមមាន ក្រុមបុរសរួមភេទជាមួយបុរស (MSM) ក្រុមបំប្លែងភេទ (TG) ក្រុមស្ត្រីបម្រើក្នុងសេវាកំសាន្ត (FEW) និងក្រុមប្រើប្រាស់គ្រឿងញៀន (PWID) មានចំនួនកើនឡើង និងមានអត្រាឆ្លងមេរោគអេដស៍ខ្ពស់។ ដោយឡែកក្រុមយុវវ័យអាយុពី១៥-២៤ឆ្នាំ កំពុងមានអត្រាឆ្លងថ្មីខ្ពស់រហូតដល់៤១% នៅឆ្នាំ២០២១ ដែលយើងកំពុងយកចិត្តទុកដាក់បំផុត ក្នុងការធ្វើអន្តរាគមន៍ ដើម្បីកាត់បន្ថយការរាលដាល។

ចុងបញ្ចប់ ឯកឧត្តមប្រធានអង្គប្រជុំ ក៏បានបន្ថែមថា ការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នា រវាងអ្នកធ្វើគោលនយោបាយ និងយុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងអ្នករងផលប៉ះពាល់។ ក្នុងឆ្នាំ២០២១នេះ ប្រទេសកម្ពុជា មានចំនួនអ្នកផ្ទុក

មេរោគអេដស៍ប្រមាណ ៧៤.០០០នាក់ អ្នកឆ្លងថ្មីមានចំនួនប្រមាណ១.១០០នាក់ អ្នកស្លាប់ដោយសារជំងឺអេដស៍មានចំនួនប្រមាណ១.១០០នាក់ និងអត្រាប្រេវ៉ាឡង់ ក្នុងចំណោមប្រជាជនទូទៅ(អាយុពី១៥-៤៩ឆ្នាំ) មានប្រមាណ ០.៦% និងអ្នកបានចូលក្នុងប្រព័ន្ធទទួលសេវាព្យាបាល ថែទាំដោយឱសថប្រឆាំងមេរោគអេដស៍(ARV)ដែលផ្តល់ និងគ្រប់គ្រងដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) មានចំនួនប្រមាណ ៦២.៨៣៨នាក់។

សម្រាប់កិច្ចប្រជុំលើកទី១០នឹងកំណត់យក នៅថ្ងៃអង្គារ ១កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាញ(Zoom)។

ថ្ងៃពុធ ៣កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២
អ្នកធ្វើរបាយការណ៍

ប្រធានអង្គប្រជុំ

**ឈឹម ឃិនដារ៉េត**